ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន
## អង្គជំនុំជម្រះតុលាការកំពូលបដិសេធសំណើសុំបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះ

ថ្ងៃនេះ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានសម្រេចបដិសេធសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបញ្ជូនសំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ ទៅជំនុំជម្រះ។

ដោយទទួលបានសំឡេងជាឯកច្ឆ័ន្ទ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីការខកខានរបស់អង្គបុរេជំនុំជម្រះ ក្នុងការបញ្ជូនសំណុំរឿង០០៤ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខណ្ឌគតិយុត្តរបស់អ.វ.ត.ក" អាចទទួលយកបាន ក្នុងផលប្រយោជន៍យុត្តិធម៌។ ពាក្យស្នើសុំត្រូវបានពិចារណាដោយចៅក្រមភាគច្រើននៃអង្គជំនុំជម្រះ ដែលផ្តល់ "ភាពច្បាស់លាស់និងភាពជាក់លាក់ផ្នែកច្បាប់ និង៖

១) បានបដិសេធការយល់ឃើញ របស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា សំណុំរឿង ០០៤ គួរត្រូវបញ្ជូនទៅជំនុំជម្រះ ដោយកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ មិនបានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹង យឹម ទិត្យ អនុលោមតាមវិធាន ៧៩(១) នៃវិធានផ្ទៃក្នុង។

២) បានបញ្ជាក់ថា អង្គបុរេជំនុំជម្រះបានបញ្ចប់សំណុំរឿង ០០៤ នៅពេលអង្គជំនុំជម្រះនេះបានចេញ*សេចក្តីពិចារណា*របស់ខ្លួន។

៣) បានបញ្ជាក់បំភ្លឺថា សំណុំរឿង ០០៤ ត្រូវបានបញ្ចប់ ដោយសារគ្មានដីកាបញ្ជូនរឿងទៅជំនុំជម្រះស្ថាពរ និងដែលអាចអនុវត្តបាន។

នៅក្នុងយោបល់ជំទាស់ដោយឡែករបស់គាត់ លោកស្រីចៅក្រម Maureen Harding Clark បានសន្និដ្ឋានថា "សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះពុំមានសុពលភាព និងគួរត្រូវបានច្រានចោលដោយសារវាពុំមានសនិទានភាព [...]" ហើយគួរបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង យឹម ទិត្យ។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

សេចក្តីសម្រេចនេះអាចរកមើលបាននៅលើគេហទំព័ររបស់ អ.វ.ត.ក៖ https://eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/2_1_1_1_KH.PDF

សេចក្តីប្រកាសព័ត៌មាននេះ ត្រូវបានផ្សព្វផ្សាយដោយផ្នែកកិច្ចការសាធារណៈ អនុលោមតាមវិធាន ៩(៤) និង ២១(គ) នៃវិធានផ្ទៃក្នុងដើម្បីផ្តល់ព័ត៌មានដល់សាធារណជន។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក នេត្រ ភក្ត្រា**

ប្រធានផ្នែកកិច្ចការសាធារណៈ និងជាអ្នកនាំពាក្យ

ទូរស័ព្ទ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦

អ៊ីមែល៖ neth.phektra@eccc.gov.kh